ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៦-៥-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៥១១/៣៩២ ស្តីពី ការតែងតាំង លោក លី ស៊ុខហួ ជាឧកញ៉ា ៣៨០៥

១៦-៥-២០១១ -ព្រះរាជក្រឹត្យ នស/រកត/០៥១១/៣៩៥ ស្តីពី ការផ្លាស់ឯកឧត្តម ណាន់ ស៊ី បច្ចុប្បន្នឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសប៊្រុយណេ ដារូសាឡឹម វិលចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ៣៨០៦


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៨-៥-២០១១ -អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្តីពី ការបង្កើតខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ ៣៨០៧

១៨-៥-២០១១ -អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៣៨០៩

១៩-៥-២០១១ -អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៣៨១១

១០-៥-២០១១ -អនុក្រឹត្យលេខ ៥៣៧ អនក្រ.តត ស្តីពី ការ តម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៣៨១៤

១១-៥-២០១១ -អនុក្រឹត្យលេខ ៥៣៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៣៨១៦

១១-៥-២០១១ -អនុក្រឹត្យលេខ ៥៣៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៣៨១៨

១១-៥-២០១១ -អនុក្រឹត្យលេខ ៥៤០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨២១

១១-៥-២០១១ -អនុក្រឹត្យលេខ ៥៤១ អនក្រ.តត ស្តីពី ការ ជូនមេដាយសហមេត្រី ៣៨២៤

១១-៥-២០១១ -អនុក្រឹត្យលេខ ៥៤២ អនក្រ.តត ស្តីពី ការ តម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់ ៣៨២៥

១២-៥-២០១១ -អនុក្រឹត្យលេខ ៥៤៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨២៦

១២-៥-២០១១ -អនុក្រឹត្យលេខ ៥៤៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៣៨២៧

១២-៥-២០១១ -អនុក្រឹត្យលេខ ៥៤៥ អនក្រ.តត ស្តីពី ការ ជូនមេដាយសហមេត្រី ៣៨២៨

១២-៥-២០១១ -អនុក្រឹត្យលេខ ៥៤៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៣៨២៩

## ២-សារាចរណែនាំ

១៨-៥-២០១១ -សារាចរណែនាំលេខ ០៦ សរណន ស្តីពី ការរៀបចំខួបលើកទី ៦២ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី ១០ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា និង ទិវាកុមារកម្ពុជា ឆ្នាំ ២០១១ ៣៨៣០

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១៨-៥-២០១១ -សេចក្តីជូនដំណឹងលេខ០០៦ សហវ.អពដ ស្តីពីការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យ ៣៨៣៣

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២៥៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីបើរ-បាហ្វ ហ្វីរសទ្រី & ផ្លែនថេសិន** ៣៨៣៥

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២៦១ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេស៊ីហ្វិក ប្រូស្រស យ៉ាញ-ស្ទុត ខមភេនី លីមីធីត** ៣៨៣៧

១៣-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២៦២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផេស៊ីហ្វិក ខិតថឺរ៍ យ៉ាញ-ស្ទុត ខមភេនី លីមីធីត** ៣៨៣៩

១៤-៧-២០១០ -លិខិតបញ្ជាក់លេខ ៣២៦៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.អេច.ស៊ី.ឌី. អេហ្វ្រិកខលឈ័រ** ៣៨៤១

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៣៩២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

តែងតាំង

លោក លី ស៊ុនហួ

ជា

ឧកញ៉ា

៣រល.១១០៥.៣៩៧

ធ្វើនៅព្រះបរមរាជវាំង . ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៣៧៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១១
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥១១/៣៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពី លក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១.-** ត្រូវបានផ្លាស់ឯកឧត្តម **ណាន់ ស៊ី** បច្ចុប្បន្ន ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសប្រ៊ុយណេ ដារូសាឡឹម វិលចូលប្រទេសវិញ ដោយត្រូវ ចប់អាណត្តិបេសកកម្ម ។

**មាត្រា ២.-** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល. ១១០៥.៤០០

លេខ: ៣៨០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៧ [illegible] ឆ្នាំ២០១១
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

ឃុន ជិនកេន

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៩០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០២០ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១០/៧៦៣ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងរាជធានីភ្នំពេញ និងខេត្តកណ្តាល ដោយកាត់យកឃុំចំនួន ២០ នៃខេត្តកណ្តាល មកបញ្ចូលក្នុងរាជធានីភ្នំពេញ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

**មាត្រា ១.-**

ត្រូវបានបង្កើត **ខណ្ឌពោធិ៍សែនជ័យ** នៃរាជធានីភ្នំពេញ ដោយកាត់យកសង្កាត់ចំនួន ១៣ ពីខណ្ឌដង្កោ នៃរាជធានីភ្នំពេញ គឺ សង្កាត់ចោមចៅ សង្កាត់កាកាប សង្កាត់ក្រាំងធ្នង់ សង្កាត់គោករកា សង្កាត់សំរោងក្រោម សង្កាត់ពន្សាំង សង្កាត់ត្រពាំងក្រសាំង សង្កាត់ស្នោរ សង្កាត់ឪឡោក សង្កាត់កំបូល សង្កាត់កន្ទោក សង្កាត់បឹងធំ និងសង្កាត់ភ្លើងឆេះរទេះ ។

ព្រំប្រទល់រដ្ឋបាលនៃ**ខណ្ឌពោធិ៍សែនជ័យ** ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានផ្ទេរទីតាំងសាលាខណ្ឌដង្កោ ដែលស្ថិតនៅក្នុងសង្កាត់កាកាប ទៅជាសាលា**ខណ្ឌពោធិ៍សែនជ័យ** ។

**មាត្រា ៣.-**

ទីតាំងសាលាខណ្ឌដង្កោ ត្រូវស្ថិតនៅក្នុងសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរដ្ឋបាល **ខណ្ឌពោធិ៍សែនជ័យ** ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ក្រុមប្រឹក្សារាជធានីភ្នំពេញ គណៈអភិបាលរាជធានីភ្នំពេញ ក្រុមប្រឹក្សាខណ្ឌដង្កោ គណៈអភិបាលខណ្ឌដង្កោ និងក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១០/០១៧ , ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋាន មួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧០ អនក្រ.បក. ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិ តាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០១១
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៤០០ លានរៀល (បួនរយលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦១ (សេវាខាងក្រៅ) ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សំរាប់ការគ្រប់គ្រងឆ្នាំ ២០១១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ជួសជុល និងផ្លាស់ប្តូរគ្រឿងបន្លាស់ ត្រាក់ទ័រចំនួន ៤២ គ្រឿង របស់អគ្គបញ្ជាការដ្ឋានអង្គរក្ស ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជំរាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល។

## សម្រេច

**មាត្រា១ៈ**

គ្រូវបានកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ដែនជម្រកសត្វព្រៃបឹងពែរ លើផ្ទៃដីចំនួន ៩.៩១៦ (ប្រាំបួនពាន់ ប្រាំបួនរយ ដប់ប្រាំមួយ)ហិកតា ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះវិហារ សម្រាប់ផ្តល់ជូនក្រុមហ៊ុន **ទ្រី ភាព អ៊ីមផត អ៊ិចផត**(Try Pheap Import Export Co., Ltd) ធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ ដែលមានទីតាំង និងនិយាមកាដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ៥២៤ សជណ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១១ជាឧបសម្ព័ន្ធ។

**មាត្រា២៖**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីគោរពជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទី ទីតាំងដីវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ របស់ក្រុមហ៊ុន ភាព អ៊ីមផត អ៊ិចផត (PHEAP Import Export Co., Ltd.) ស្ថិតនៅក្នុងដែនជម្រកសត្វព្រៃបឹងពែរ ឃុំសាស្រ្ត ស្រុករវៀង ខេត្តព្រះវិហារ លើផ្ទៃដី ៩៩១៦ ហិកតា







| Id | N | X | Y |
|---|---|---|---|
| 1 | A | 504407 | 1463401 |
| 2 | B | 507540 | 1463480 |
| 3 | C | 509940 | 1461121 |
| 4 | D | 510422 | 1456746 |
| 5 | E | 511399 | 1454911 |
| 6 | F | 511956 | 1452256 |
| 7 | G | 506532 | 1449314 |
| 8 | H | 504737 | 1447954 |
| 9 | I | 500622 | 1444779 |
| 10 | J | 497972 | 1447758 |
| 11 | K | 499450 | 1449548 |
| 12 | L | 503329 | 1452256 |
| 13 | M | 506163 | 1455040 |
| 14 | N | 506213 | 1457222 |
| 15 | O | 505696 | 1459865 |

**សញ្ញាសំគាល់**

- • ចំណុចទិសាមគា
- ទីតាំងដីវិនិយោគ
- ផ្លូវជាតិ
- ផ្លូវលំ
- ស្ទឹង អូរ
- ព្រំប្រទល់ដែនជម្រកសត្វព្រៃបឹងពែរ

ផែនទី ទីតាំងវិនិយោគនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ៥៧៤ សជណ
ចុះថ្ងៃទី [illegible] ឆ្នាំ ២០១១
[illegible]

ផែនទី ទីតាំងវិនិយោគនេះ ជាឯកសារ
ភ្ជាប់នឹងលិខិតលេខ ៩៦០ កសក
ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១១
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
[illegible]

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៣៧អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម ៖

១- លោកស្រីវរសេនីយ៍ទោ **ឈាន គីមស៊ុន** អត្តលេខ ០៨១៣

២- លោកវរសេនីយ៍ទោ **ណុប សិរីយុទ្ធ** អត្តលេខ ០១៥៣៦

៣- លោកវរសេនីយ៍ទោ **ស៊ុ គីមហាក់** អត្តលេខ ០១៥៧៧

៤- លោកវរសេនីយ៍ទោ **អ៊ុំ ឯម** អត្តលេខ ០១៦៨៩

៥- លោកស្រីវរសេនីយ៍ទោ **អ៊ុក សុខុម** អត្តលេខ ០១៧២៣

៦- លោកស្រីវរសេនីយ៍ទោ **សេង សេរីរដ្ឋា** អត្តលេខ ០១៨៣៤

៧- លោកស្រីវរសេនីយ៍ទោ **ចឹក ផល្លា** អត្តលេខ ០១៨៨៦

៨- លោកវរសេនីយ៍ទោ **សៀង ហោ** អត្តលេខ ០២៣៣០

៩- លោកវរសេនីយ៍ទោ **តិន យ៉ាន** អត្តលេខ ០២៣៣៨

១០- លោកវរសេនីយ៍ទោ **រតន៍ ម៉ូរ៉ា** អត្តលេខ ០២៩៦៨

១១- លោកស្រីវរសេនីយ៍ទោ **ប៊ី សារិន** អត្តលេខ ០៣៤២៤

១២- លោកស្រីវរសេនីយ៍ទោ **នៃ សំណាង** អត្តលេខ ០៣៤២៦

១៣- លោកវរសេនីយ៍ទោ **ពុទ្ធិ ខ៊ុំប** អត្តលេខ ០៤៧៥១

១៤- លោកស្រីវរសេនីយ៍ទោ **សាត់ ម៉ី** អត្តលេខ ០៧៨៧៩

១៥- លោកស្រីវរសេនីយ៍ទោ **ប្រាក់ សៅនី** អត្តលេខ ០៩០២៤ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ១៨រូប ដែលមានស្នាដៃល្អក្នុងការជួយអភិវឌ្ឍន៍មូលដ្ឋាន នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ និបឝិន្ទ**

១-សម្តេចព្រះមហាអរិយវង្ស **សៅរី ចន្ទថុល្ល** ព្រះបាឡាត់គណរាជធានីភ្នំពេញ និងជាព្រះចៅអធិការវត្តលង្កា បច្ច័យ ៧៨៩០០ដុល្លា

២-ឯកឧត្តម **ឆន្លាប់ ណុន** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាថវិកា៦៨៦០០ដុល្លា

៣-ឯកឧត្តម **ច័ន្ទ ចណ្ណៈ** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាថវិកា៦៨៦០០ដុល្លា

៤-ឯកឧត្តម **ឈឹម នែម** ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភាថវិកា៦៨៦០០ដុល្លា

៥-លោក **គុជ ហានស៊ីន** អគ្គនាយករង នៃអគ្គនាយកដ្ឋានអប់រំ អយក

៦-លោក **គួច គួលំអ** ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១-ព្រះអរិយមគ្គញាណ **សូរ សារិទ្ធី** ព្រះចៅអធិការវត្តឧបបច្ច័យ៣៦០០០ដុល្លា

២-ព្រះពោធិវង្សា **ថាន់ ចន្ទតារា** គ្រូសូត្រឆ្វេងវត្តលង្កា បច្ច័យ៣៥១០០ដុល្លា

៣-ព្រះបវរវិជ្ជា **ស៊ឹម សារ៉ាន** ព្រះវិន័យធរវត្តលង្កា បច្ច័យ៣៥២០០ដុល្លា

៤-ព្រះគ្រូពិភ័ក្តិមុនី **លឹម ឿន** ជំនួយការផ្ទាល់សម្តេចព្រះសុមេធា **នន្ទ ង៉ែត** និងជាព្រះចៅអធិការវត្តពិគខ្សៀបច្ច័យ ៤២៨០០ដុល្លា

៥-លោក **ព្រាំ ធុ** ប្រធានការិយាល័យដឹកជញ្ជូន មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តស្វាយរៀង ថវិកា៣៧១០០ដុល្លា

៦-លោកស្រី **ម៉ុក សុម៉ាលី**សប្បុរសជននៅខេត្តស្វាយរៀង ថវិកា៣៦០០០ដុល្លា

៧-លោក **ម៉េង ហ៊ាង** សប្បុរសជននៅខេត្តកំពង់ចាម ថវិកា៣៧៣០០ដុល្លា

៨-លោក **តាំង គួងហាង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា៣៥១០០ដុល្លា

៩-លោកស្រី **ពុំ ស្មារណា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា៣៥០០០ដុល្លា

១០-ឧបាសិកា **ធុ ហៀង** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា៣៦៥០០ដុល្លា

១១-ឧបាសិកា **មិន កនិកា** សប្បុរសជននៅរាជធានីភ្នំពេញ ថវិកា៣៥៥៦០ដុល្លា

១២-ឧបាសិកា **អ៊ុច យ៉ាន់** សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល ថវិកា៣៧១៣០ដុល្លា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៣៧ អនក្រ.តត

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយការងារ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រីរាជការ តាមមូលដ្ឋាន ចំនួន ៦២រូប ដែលមានស្នាដៃល្អ ក្នុងការជួយអភិវឌ្ឍន៍មូលដ្ឋាន នាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-លោកវរសេនីយ៍ត្រី **មាំង ពេច** អត្តលេខ២០៣៦៣៥អធិការស្រុកស្អាង ខេត្តកណ្តាល

២-លោកអនុសេនីយ៍ឯក **អ៊ូ ផល្លី** អត្តលេខ២០៤៦៩៨៨មេបញ្ជាការកងរាជអាវុធហត្ថស្រុកស្អាង ខេត្តកណ្តាល

៣-លោកអនុសេនីយ៍ទោ **ម៉ៃ សារិន**អត្តលេខ១៣២៣៧មេប៉ុស្តិ៍ឃុំខ្ពបស្រុកស្អាង ខេត្តកណ្តាល

៤-ព្រះមហា **លយ ធី** ព្រះសង្ឃវត្តឧណ្ណាលោម

៥-ព្រះមហា **ឡុច ម៉ៃ** លេខាធិការវត្តមហាមន្ត្រី

៦-ព្រះមហា **ឆេង ឆវណ្ណធី** ព្រះវិន័យធរវត្តសារាវន្តតេជោ

៧-លោក **ឆោម ឆេងហ៊ាង** អធិការរងពុទ្ធិកសិក្សា

៨-លោក **តាំង រតនា** ប្រធានការិយាល័យបកស្រាយច្បាប់នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

៩-លោក **ឌួន សឿន** ប្រធានការិយាល័យ មន្ទីរធម្មការស្រុកស្អាង ខេត្តកណ្តាល

១០-លោកវរសេនីយ៍ឯក **ចាន់ ចន** អត្តលេខ២០១២១០៧ ស្នងការរងនគរបាលខេត្តព្រៃវែង

១១-លោក **ចេង សុវណ្ណ** មន្ត្រីសាលាភូមិន្ទរដ្ឋបាល

១២-លោកស្រី **ច្រឹង វណ្ណារ៉ា** មន្ត្រីសាលាភូមិន្ទរដ្ឋបាល

១៣-លោក **ញ៉ែម សុលីវ៉ាន់** អនុប្រធាននាយកដ្ឋាន ក្រសួងផែនការ

១៤-លោក **ហេង កំសាន** អនុប្រធាននាយកដ្ឋាន ក្រសួងវប្បធម៌

១៥-អ្នកគ្រូ **ឡុង និមល** សាស្ត្រាចារ្យវិទ្យាល័យទីរួមខេត្ត

១៦-លោក **ថាន់ សុខតា** មន្ត្រីរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

១៧-លោកអនុសេនីយ៍ឯក **ជឹម ស៊ីថា** អត្តលេខ ១៣១០៤ អធិការរងនគរបាលខណ្ឌមានជ័យ

១៨-លោកស្រី **សំ ធីតា** មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា

១៩-លោកស្រី **ឃឹម ម៉ារុំ** មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ

២០-លោកស្រី **អំណាត់ តន្នី** មន្ត្រីរតនាគាររាជធានីភ្នំពេញ

២១-លោក **អំណាត់ តក្ក** ប្រធានការិយាល័យ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល

២២-លោក **យ៉េន សុខា** អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក

២៣-លោក **ឈិន ខុត** អនុប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក

២៤-លោក **តុត សិទ្ធី** ប្រធានការិយាល័យទិន្នន័យ និងព័ត៌មាន នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក

២៥-លោកអនុសេនីយ៍ទោ **ជួប សុគន្ធ** អត្តលេខ ០១៦៥៩៤ នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលផ្សារថ្មីទី ២

២៦-លោកអនុសេនីយ៍ត្រី **ឯម មរុ** អត្តលេខ ០១៧៥០៧ នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលផ្សារថ្មីទី ២

២៧-លោកអនុសេនីយ៍ត្រី **ហោង ដារ៉ា** អត្តលេខ ០១៧៥២៨ នាយរងប៉ុស្តិ៍នគរបាលរដ្ឋបាលផ្សារថ្មីទី ២

២៨-ឯកឧត្តម **ឃុន សុផល** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់

២៩-ឯកឧត្តម **ថា ពិសី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់

៣០-ឯកឧត្តម **ឆេង សុផាត** ទីប្រឹក្សាក្រសួងមហាផ្ទៃ

៣១-ឯកឧត្តម **សុខ ហ៊ី** ទីប្រឹក្សាក្រសួងមហាផ្ទៃ

៣២-ឯកឧត្តម **ស៊ឹម សារឿន** ជំនួយការអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

៣៣-លោក **ថោង អ៊ុំសុធារី** អនុប្រធានការិយាល័យរដ្ឋបាល មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តស្វាយរៀង

៣៤-លោកសាស្ត្រាចារ្យ **ហាប់ សុខចំណាន**សាស្ត្រាចារ្យសាកលវិទ្យាល័យស្វាយរៀង

៣៥-លោកស្រី **ព្រហ្ម កែវរស្មី** មន្ត្រីសាលាខេត្តស្វាយរៀង

៣៦-លោកស្រី **ព្រហ្ម រីណា** មន្ត្រីមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តស្វាយរៀង

៣៧-លោក **សុន សិ** អនុប្រធាននាយកដ្ឋានក្រសួងយុត្តិធម៌

៣៨-លោក **សូ យុនថរក្ស** ប្រធាននាយកដ្ឋាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

៣៩-លោក **ប្រាក់ ផាន់ណារ៉ា** ជំនួយការទីស្តីការគណៈរដ្ឋមន្ត្រី

៤០-លោក **ទ្រី ថាន់ថា** មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

៤១-លោក **សួន សុភា** អនុប្រធាននាយកដ្ឋានទីស្តីការគណៈរដ្ឋមន្ត្រី

៤២-លោក **ហូ ពុទ្ធា** អនុប្រធាននាយកដ្ឋានក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

៤៣-លោក **ហែម ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានក្រសួងមហាផ្ទៃ

៤៤-លោក **យាវ ផលសាយ** ប្រធានការិយាល័យរដ្ឋបាល នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក

៤៥-លោក **អ៊ី សុខឡេង** អនុប្រធាននាយកដ្ឋានក្រសួងមហាផ្ទៃ

៤៦-លោក **អ៊ុំ ម៉ាសាយុណា** អនុប្រធាននាយកដ្ឋានក្រសួងមហាផ្ទៃ

៤៧-លោក **ប៊ុន ពិសិដ្ឋ** អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

៤៨-អ្នកស្រី **ភង សុចាវ** ប្រធានការិយាល័យក្រោយអក្ខរកម្ម នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក

| | |
|---|---|
| ៤៩-លោក **មុនី ថរៈ** | ប្រធាននាយកដ្ឋាន ក្រសួងមហាផ្ទៃ |
| ៥០-លោក **ឆន សំណាង** | អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា |
| ៥១-លោក **ឈុន ហូត** | ប្រធាននាយកដ្ឋានទីស្តីការគណៈរដ្ឋមន្ត្រី |
| ៥២-លោក **សំ ចាន់និត** | ប្រធានការិយាល័យអគ្គរកម្ម នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក |
| ៥៣-លោក **ញ៉ែម ធីម** | ប្រធានការិយាល័យព័ត៌មានផ្សព្វផ្សាយ នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក |
| ៥៤-លោក **ញ៉ែម ភណារ៉ែត** | អនុប្រធានការិយាល័យរដ្ឋបាល នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក |
| ៥៥-លោក **អ៊ុច សារីត** | អនុប្រធានការិយាល័យបំពេញវិជ្ជា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក |
| ៥៦-លោក **ប៊ិច ហ៊ា** | អនុប្រធានការិយាល័យទិន្នន័យ និងព័ត៌មាន នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក |
| ៥៧-លោក **តាល់ វណ្ណារ៉ា** | អនុប្រធានការិយាល័យបំពេញវិជ្ជា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ អយក |
| ៥៨-លោក **ហាយ កុសល** | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៥៩-លោក **សែម ពិសី** | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៦០-លោក **ប៉ា ហ៊ាន់ហាន** | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៦១-លោក **វង ភកសុផាណា** | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៦២-លោក **អ៊ឹម ពិរុណា** | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ហាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ហាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ៤៦រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ព្រមទាំងធនធាន ក្នុងការជួយអភិវឌ្ឍន៍ជាតិមាតុភូមិ នាពេលកន្លងមក ដូចមានរាយនាមខាងក្រោមៈ

**ក-មេដាយមាសស្ហាបនាជាតិ**

| | | |
|---|---|---|
| ១-ឧបាសក **ពួរ ហ៊ីត** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា១២០០០ដុល្លា |
| ២-ឧបាសិកា **ប៉ុល គ្រេម** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកា១១៦០០ដុល្លា |
| ៣-លោក **ឌួង សុខ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១១៣២០ដុល្លា |
| ៤-លោក **ឈួរ ថាច** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១១៣២០ដុល្លា |
| ៥-ព្រះតេជគុណ **នូ សាំង** | ព្រះចៅអធិការវត្តព្រែកជ្រៃ | បច្ច័យ១១៣០០ដុល្លា |
| ៦-ឧបាសក **សុខ ជួ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១១២០០ដុល្លា |
| ៧-ឧបាសិកា **គង់ ទ៉ាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១១១០០ដុល្លា |
| ៨-លោក **ព្រុំ ឈឹន** | ប្រធានក្រុមប្រឹក្សាស្រុកស្អាង | ថវិកា១១០០០ដុល្លា |
| ៩-លោក **ខឹម ច័ន្ទតរី** | អភិបាល នៃគណអភិបាលស្រុកស្អាង | ថវិកា១១០០០ដុល្លា |
| ១០-លោកស្រី **លី គមស៊ាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១១០០០ដុល្លា |
| ១១-ឧបាសិកា **យ៉ាង សារ៉យ៉េន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១១១០០ដុល្លា |

| | | |
|---|---|---|
| ១២-លោក **លី ចន្ទឌី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១១៣២០ដុល្លា |
| ១៣-លោក **អ៊ាប ប៊ុនថាន** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១០៣០០ដុល្លា |
| ១៤-លោក **គម ជាឧុច** | ប្រធានការិយាល័យបំពេញវិជ្ជា ន.អប់រំក្រៅប្រព័ន្ធ អយក | ថវិកា១២៦០០ដុល្លា |
| ១៥-អ្នកស្រី **ឈាង បូនី** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១២៦០០ដុល្លា |
| ១៦-លោកជំទាវ **ផេង រតនា ច័ន្ទ ចណ្ណា:** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១២៦០០ដុល្លា |
| ១៧-លោកជំទាវ **សំ ច័ន្ទថេរ៉ាថ ឈឹម ឆៃម** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១២៦០០ដុល្លា |
| ១៨-លោក **ហ៊ុយ រ៉េកុល** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា១២៦០០ដុល្លា |
| ១៩-ព្រះតេជគុណ **ឡោ សារ៉ុម** | ព្រះចៅអធិការវត្តប្រជុំវង្សី(វត្តព្រែកក្តាម) | បច្ច័យ១១០០០ដុល្លា |
| ២០-ឧបាសក **សួន យ៉េម** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា១០០០០ដុល្លា |
| ២១-ឧបាសក **គម យន់** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា២៩១១៨ដុល្លា |
| ២២-ឯកឧត្តម **ឡាច ម៉េងលី** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា១០៥០០ដុល្លា |
| ២៣-លោក **ស៊ឹម សែ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា១០៦០០ដុល្លា |
| ២៤-លោក **ឌី សាខន** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា១០០០០ដុល្លា |
| ២៥-លោក **ប៉ុក អ៊ុច** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា១០០០០ដុល្លា |
| ២៦-លោក **ឃឹម សុផល** | មេឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល | ថវិកា១០០០០ដុល្លា |
| ២៧-លោក **កេត ចាន់សុវណ្ណី** | ប្រធានប៉ុស្តិ៍រដ្ឋបាលនគរបាលឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល | ថវិកា១០០០០ដុល្លា |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | |
|---|---|---|
| ១-លោក **ជុច ម៉េងខាង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា៥៥០០ដុល្លា |
| ២-ឧបាសក **ហែម ឌុច** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៥០០ដុល្លា |
| ៣-ឧបាសិកា **មុត ធីម** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៤០០ដុល្លា |
| ៤-លោក **ដៃ ជឿន** | អនុប្រធានគណកម្មការវត្តឧប ស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៤០០ដុល្លា |
| ៥-ឧបាសិកា **អ៊ិង អោក** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៤០០ដុល្លា |
| ៦-ឧបាសិកា **ស៊ាន គមលាន** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥១០០ដុល្លា |
| ៧-ឧបាសិកា **ប៉ុក់ សាខន** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៥០០ដុល្លា |
| ៨-ឧបាសក **ឌុយ ឈ្លាន** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៥០០ដុល្លា |
| ៩-លោកស្រី **សុខ បុល** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៥០០ដុល្លា |
| ១០-លោក **ហែម សំអាត** | នាយកអនុវិទ្យាល័យឧបស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥៤០០ដុល្លា |
| ១១-លោកស្រី **កាក់ ចាន់ផល្លា** | នាយិកាសាលាបឋមសិក្សាវត្តឧបស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥២០០ដុល្លា |
| ១២-ឧបាសក **កែវ សេង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកា៥២០០ដុល្លា |
| ១៣-ឧបាសិកា **អ៊ូ ចាន់** | សប្បុរសជននៅស្រុកស្អាង ខេត្តកណ្តាល | ថវិកា៥២០០ដុល្លា |
| ១៤-ឧបាសិកា **ឈឹន អេង** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា៥០០០ដុល្លា |
| ១៥-ឧបាសិកា **ប៊ុន រ៉ាថ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា៥៥០០ដុល្លា |
| ១៦-ឧបាសិកា **គក អេងគ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា៥០០០ដុល្លា |
| ១៧-លោក **ប៉ោ តុល** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា៥០០០ដុល្លា |
| ១៨-លោក **ចោង សុខារិទ្ធ** | សប្បុរសជននៅខេត្តកណ្តាល | ថវិកា៦១០០ដុល្លា |

១៩-លោក **លី ឡេង** សប្បុរសជននៅខេត្តកណ្តាល ថវិកា៥០០០ដុល្លា

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤១ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ /១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស / រកត / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនយោធាចារ្យ និង សប្បុរសជននៃសាធារណរដ្ឋឥណ្ឌូនេស៊ី ចំនួន ០៦ រូប ដែលមានស្នាដៃល្អ ក្នុងការលើកស្ទួយទំនាក់ទំនងមិត្តភាព និង កិច្ចសហប្រតិបត្តិការល្អជាមួយបញ្ជាការដ្ឋានអង្គរក្ស ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១- លោក | Mayjen TNI (MG) Suwarno | អតីតៈមេបញ្ជាការអង្គរក្សប្រធានាធិបតីឥណ្ឌូនេស៊ី |
| ២- លោកជំទាវ | Nita Riana Brigjen | ភរិយាមេបញ្ជាការរងអង្គរក្សប្រធានាធិបតីឥណ្ឌូនេស៊ី |
| ៣- លោក | Mayor Inf Suprapto | យោធាចារ្យឥណ្ឌូនេស៊ី |
| ៤- លោក | Kapten Inf Supriyadi | យោធាចារ្យឥណ្ឌូនេស៊ី |
| ៥- លោក | Kapten Czi Abbas | យោធាចារ្យឥណ្ឌូនេស៊ី |
| ៦- លោក | Serka Antonio B | យោធាចារ្យឥណ្ឌូនេស៊ី |

**មាត្រា២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ**...៥៤៧...អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាតិជាន់ខ្ពស់

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ *វរសេនីយ៍ឯក* ជូនលោកវរសេនីយ៍ទោ **ហៀង គីមឈៀង** អត្តលេខ ០១១៥១ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សម្រេច

**មាត្រា ១** : តែងតាំងលោកបណ្ឌិត **សាផុន ខឡុនៈ** ជាសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជំនួសលោក យក់ សុជាន់ណា ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់**មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ផ្តល់ជូនសប្បុរសជនចំនួន ០៤ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសាលាមត្តេយ្យ ចំនួន០២ខ្នង ស្ថិតនៅក្នុងឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានរាយនាមដូចខាងក្រោម :

**ក- មេដាយមាសស្ថាបនាជាតិចំនួន ០១ គ្រឿង ផ្តល់ជូន**

លោក **អ៊ូ ម៉ិញហួរ** ប្រធានចាត់ការទូទៅសហគ្រាសតៃយៀន និងខាំវែល ថវិកាចំនួន ១៥.៣០០ ដុល្លារ

**ខ- មេដាយប្រាក់ស្ថាបនាជាតិចំនួន ០៣ គ្រឿង ផ្តល់ជូន :**

១-លោក **ហ្គ្រេក ព្រីយ៉ាឌី** (GRAG PRIYADI) នាយកអង្គការ JSC ថវិកាចំនួន ៥.២០០ ដុល្លារ

២-លោក **ឡុង សុផល** អ្នកសម្របសម្រួលអង្គការ JSC ថវិកាចំនួន ៥.០០០ ដុល្លារ

៣-លោកស្រី **ស៊ុម ណារាង** តំណាងសមាគមកសិករក្រីក្រអង្គការ JSC ថវិកាចំនួន ៥.០០០ ដុល្លារ

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តកណ្តាល និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៥៤៥ .អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយសហមេត្រី ថ្នាក់ សេនា ជូនលោក **យូក្យុង វ៉ាង** (Mr. Youquiong Wang) មន្ត្រីគ្រប់គ្រងគម្រោង ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ ក្នុងការធ្វើកិច្ចសហប្រតិបត្តិការ សម្របសម្រួល និងផ្តល់ហិរញ្ញប្បទាន ពីមូលនិធិអន្តរជាតិ សម្រាប់អភិវឌ្ឍន៍កសិកម្ម នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៤៦.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០៩ / ៦០៨ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ / ៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១០ ស្តីពីការកែសំរួលមាត្រា៣៥ នៃព្រះរាជក្រឹត្យ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
-បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
-តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងលោកឧត្តមសេនីយ៍ទោ **គីម ចាន់នី** អត្តលេខ ០០៦៧ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ១២ ខែ ឧសភា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦. សរ៣ន

**សារាចរណែនាំ**
**ស្តីពី**
**ការរៀបចំខួបលើកទី ៦២ ទិវាកុមារអន្តរជាតិ ១ មិថុនា**
**ខួបលើកទី ១០ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា**
**និងទិវាកុមារកម្ពុជាឆ្នាំ ២០១១**

ជារៀងរាល់ឆ្នាំ ព្រះរាជាណាចក្រកម្ពុជាតែងបានប្រារព្ធទិវាកុមារអន្តរជាតិ **១ មិថុនា** និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ដើម្បីរំលឹកដល់ការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមារ ស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ និងអនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ការប្រារព្ធទិវាកុមារអន្តរជាតិ **១ មិថុនា** គឺដើម្បីរំលឹកដល់វិនាសកម្មនៃការកាប់សម្លាប់ស្ត្រី និងកុមារនៅភូមិលីឌីសែ ប្រទេសឆេក និងភូមិអូរាឌូ ប្រទេសបារាំង ដោយពួកហ្វាសស៊ីសអ៊ីត្លែរក្នុងអំឡុងឆ្នាំ ១៩៤២-១៩៤៤ នៃសង្គ្រាមលោកលើកទី ២ និងក្នុងគោលបំណងឱ្យមនុស្សជាតិទាំងអស់ចងចាំ និងរំងាប់ចោលនូវអំពើហិង្សា ដើម្បីថែរក្សាសន្តិភាពក្នុងពិភពលោក។

រីឯការប្រារព្ធទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ គឺដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ ដូចជា ទាសករកុមារ ការជួញដូរកុមារ ពេស្យាចារកុមារ ការប្រើប្រាស់កុមារក្នុងជម្លោះប្រដាប់អាវុធ និងក្នុងស្ថានភាពងាយរងគ្រោះ។ យោងតាមរបាយការណ៍របស់អង្គការពលកម្មអន្តរជាតិ ក្នុងពិភពលោកមានកុមារប្រមាណជាង **១១៥** លាននាក់ អាយុពី ៥ ដល់ ១៧ ឆ្នាំ កំពុងរងគ្រោះដោយទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ ហេតុនេះទើបអង្គការពលកម្មអន្តរជាតិសម្រេចយកថ្ងៃទី **១២ ខែ មិថុនា** ជារៀងរាល់ឆ្នាំ ដើម្បីរៀបចំទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ។

ព្រះរាជាណាចក្រកម្ពុជាធ្លាប់បានទទួលរងមហាវិនាសកម្មដ៏ធ្ងន់ធ្ងរបង្កឡើងដោយរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានធ្វើឱ្យប្រជាជន យុវជន និងកុមារ បាត់បង់សិទ្ធិជាមនុស្ស និងត្រូវបានបង្ខំឱ្យធ្វើការជាទម្ងន់ រស់នៅយ៉ាងសែនវេទនា ទទួលរងនូវទារុណកម្ម និងការកាប់សម្លាប់ដោយអយុត្តិធម៌យ៉ាងព្រៃផ្សៃអស់រាប់លាននាក់។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ សិទ្ធិរបស់ប្រជាពលរដ្ឋ ជាពិសេសសិទ្ធិរបស់កុមារនៅកម្ពុជាត្រូវបានការពារ និងលើកតម្កើងដោយរាជរដ្ឋាភិបាល ដូចដែលមានចែងយ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញ និងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនឹងនេះ ដើម្បីបុព្វហេតុរបស់កុមារ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា និងពិធីសារជាច្រើន រួមមាន ៖ *មួយ* អនុសញ្ញាស្តីពីសិទ្ធិកុមារ នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២ *ពីរ* ពិធីសារស្តីពីការចូលរួមរបស់កុមារនៅក្នុងជម្លោះប្រដាប់អាវុធ និងពិធីសារស្តីពីការជួញដូរកុមារ ការធ្វើពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ នៅឆ្នាំ ២០០២ និង

បីរអនុសញ្ញាលេខ ២៩ ស្តីពីការងារដោយបង្ខំ ឬជាកាតព្វកិច្ចនៅឆ្នាំ ១៩៧០ អនុសញ្ញាលេខ ១៣៨ ស្តីពីការកម្រិតអាយុអប្បបរមាសម្រាប់ការចូលធ្វើការនៅឆ្នាំ ១៩៩៩ អនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្ម កុមារនៅឆ្នាំ ២០០៥ និងអនុសញ្ញាឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការសុំកូនអន្តរប្រទេស នៅឆ្នាំ ២០០៧ និងបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាពាក់ព័ន្ធនឹងកុមារមួយចំនួនទៀត ។ បន្ថែមទៀត នោះ រាជរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ស្តីពីកម្ពុជាដើម្បីកុមារនៅឆ្នាំ ២០០៤ ហើយព្រះរាជាណាចក្រកម្ពុជា ក៏បានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសវៀតណាម ប្រទេសថៃ និងកិច្ចព្រមព្រៀងជាមួយបណ្តាប្រទេសមហាអនុតំបន់មេគង្គ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ក្នុងការលុបបំបាត់ការជួញដូរកុមារនិងស្ត្រី និងជួយជនរងគ្រោះ ។

រាជរដ្ឋាភិបាលបានបង្កើនសកម្មភាពគាំទ្រ និងការពារដល់កុមារ ដើម្បីលើកស្ទួយឧត្តមប្រយោជន៍របស់កុមារ និងដើម្បីអនុវត្តឱ្យកាន់តែប្រសើរឡើងថែមទៀតនូវសិទ្ធិជាចម្បងទាំង៤របស់កុមារគឺ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម ។ ស្ថានភាពមាតាទារក ការអប់រំសិក្សា និងការការពារកុមារប្រឆាំងនឹងអំពើរំលោភបំពានផ្សេងៗត្រូវបានយកចិត្តទុកដាក់ជំរុញឱ្យកាន់តែប្រសើរឡើងជាលំដាប់ ហើយសម្រេចបានលទ្ធផលជាច្រើនតាមគោលដៅអភិវឌ្ឍសហស្សវត្ស។ ជាងនេះទៀត រាជរដ្ឋាភិបាលបានបង្កើនថវិកាលើវិស័យ សង្គមកិច្ច អប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ កសិកម្ម និងវិស័យមួយចំនួនទៀត ក្នុងគោលដៅធ្វើឱ្យសុខុមាលភាពប្រជាជនកាន់តែប្រសើរឡើងជាពិសេសចំពោះកុមារ ។ ប៉ុន្តែទន្ទឹមនឹងនេះ កុមារកម្ពុជាក៏នៅតែប្រឈមនឹងបញ្ហាមួយចំនួនទៀត ដែលយើងទាំងអស់គ្នាត្រូវរួមគ្នាដោះស្រាយឱ្យមានប្រសិទ្ធភាពខ្ពស់។ បញ្ហាទាំងនោះរួមមាន ៖ បញ្ហាអត្រាមរណមាតានិងទារក បញ្ហាគុណភាពអប់រំ ការបោះបង់ការសិក្សា បញ្ហាសមភាពយេនឌ័រ បញ្ហាគ្រឿងញៀន ការជួញដូរមនុស្ស បញ្ហាអនីតិជនទំនាស់នឹងច្បាប់ អំពើហិង្សា ការរំលោភបំពានលើកុមារ បញ្ហាកុមារកំពុងធ្វើការងារធ្ងន់ធ្ងរប្រកបដោយគ្រោះថ្នាក់ ។ល។

ដើម្បីជំរុញការអនុវត្តសិទ្ធិកុមារឱ្យកាន់តែល្អប្រសើរឡើងថែមទៀត រាជរដ្ឋាភិបាលសូមធ្វើការណែនាំឱ្យរៀបចំខួបលើកទី ៦២ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី ១០ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជា ឆ្នាំ ២០១១ នេះ ដូចតទៅ ៖

១. សម្រាប់ខួបលើកទី ៦២ ទិវាកុមារអន្តរជាតិ ១ មិថុនា និងទិវាកុមារកម្ពុជា ត្រូវប្រារព្ធក្រោមប្រធានបទ "សមធម៌សិទ្ធិរស់រានសម្រាប់កុមារគ្រប់រូប ធ្វើការរួមគ្នាដើម្បីកាត់បន្ថយអត្រាមរណភាពកុមារទូទាំងប្រទេសកម្ពុជា " ។

២. សម្រាប់ខួបលើកទី ១០ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ត្រូវប្រារព្ធក្រោមប្រធានបទ " មិនត្រូវឲ្យកុមារធ្វើការងារប្រកបដោយគ្រោះថ្នាក់ និងបញ្ចប់ពលកម្មកុមារ " ។

៣. ក្រសួងព័ត៌មានត្រូវសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ណែនាំប្រព័ន្ធឃោសនារដ្ឋ និងឯកជន ឱ្យធ្វើការផ្សព្វផ្សាយជូនដល់សង្គមជាតិទាំងមូល ឱ្យបានជ្រួតជ្រាបពីប្រវត្តិនៃទិវាកុមារអន្តរជាតិ និងទិវាកុមារកម្ពុជា ១ មិថុនា និងទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា។

៤. គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវរៀបចំពិធីមីទ្ទិញ ពិធីជួបសំណេះសំណាលជាមួយកុមារ កម្មវិធីកំសាន្តសប្បាយរបស់កុមារ នៅតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសិក្សារដ្ឋ ឯកជន អង្គការមិនមែនរដ្ឋាភិបាល និងគ្រប់មណ្ឌលកុមារកំព្រានៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានអធិកអធម។

៥. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា គណៈកម្មការជាតិរៀបចំបុណ្យជាតិ អន្តរជាតិ ៗ

សាលារាជធានីភ្នំពេញ និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការរៀបចំមីទិញថ្នាក់ជាតិ និងរៀបចំកម្មវិធីកំសាន្តផ្សេងៗសម្រាប់កុមារនៅរាជធានីភ្នំពេញឱ្យបានអធិកអធម។

៦. គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត គ្រឹះស្ថានសាធារណៈឯកជន ត្រូវរៀបចំចងបដាពាក្យស្លោកដើម្បីអបអរសាទរខួបលើកទី ៦២ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី ១០ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ ២០១១ នេះដូចតទៅ ៖

- ជយោ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបលើកទី ៦២ ទិវាកុមារអន្តរជាតិ ១ មិថុនា ខួបលើកទី ១០ ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា និងទិវាកុមារកម្ពុជាឆ្នាំ ២០១១
- សមធមិសិទ្ធិរស់រានសម្រាប់កុមារគ្រប់រូប ធ្វើការរួមគ្នាដើម្បីកាត់បន្ថយអត្រាមរណភាពកុមារទូទាំងប្រទេសកម្ពុជា
- មិនត្រូវឲ្យកុមារធ្វើការងារប្រកបដោយគ្រោះថ្នាក់ និងបញ្ចប់ពលកម្មកុមារ
- កុមារជាទំពាំងស្នងឫស្សី ជាអនាគតរបស់ប្រទេសជាតិ
- ប្តេជ្ញាបំផុសចលនាបីល្អ កូនល្អ សិស្សល្អ មិត្តល្អ របស់កុមារឲ្យបានទូលំទូលាយ

៧. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កលក្ខណៈផ្តល់ថវិកាសម្រាប់ការរៀបចំពិធីនេះឱ្យបានល្អ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានី ខេត្ត ត្រូវរៀបចំចាត់តាំងអនុវត្តក្នុងស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់។ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *គ្រប់ក្រសួង ស្ថាប័ន*
- *សាលារាជធានី ខេត្ត*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៥......សហវ.អពដ.

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១១

# សេចក្តីជូនដំណឹង
## ស្តីពី
## ការអនុវត្តប្រមូលពន្ធលើអចលនទ្រព្យ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់អចលនទ្រព្យទាំងអស់មេត្តាជ្រាបថា ពន្ធលើអចលនទ្រព្យត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ។ ពន្ធនេះត្រូវប្រមូលប្រចាំឆ្នាំ ។ ចំពោះឆ្នាំ២០១១ ពន្ធនេះត្រូវប្រមូលចាប់ពីថ្ងៃជូនដំណឹងនេះតទៅរហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ និងត្រូវកំណត់លើអចលនទ្រព្យដែលស្ថិតនៅតែក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងក្រុងនៃខេត្តនានា ដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត-ក្រុង-ស្រុក-ខណ្ឌ-ឃុំ-សង្កាត់) សម្រាប់អភិវឌ្ឍមូលដ្ឋាន ។

១- អចលនទ្រព្យដែលត្រូវបានលើកលែងពន្ធ មានដូចខាងក្រោម :

- អចលនទ្រព្យដែលជាដីធ្លីកសិកម្ម
- អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល
- អចលនទ្រព្យដែលត្រូវបានរៀបចំឡើងសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌ និងគ្មានចំណែកណាមួយ ឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន
- អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស ឬអង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា
- អចលនទ្រព្យដែលជាហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាត ឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ស្ថានីយ៍អយស្ម័យយាន
- ផ្ទះ អគារ និងសំណង់ផ្សេងៗដែលសាងសង់លើដីធ្លីកសិកម្ម ដែលបម្រើផ្ទាល់និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម
- អចលនទ្រព្យដែលទទួលរងនូវការខូចខាតធ្ងន់ធ្ងរដោយករណីប្រធានសក្តិ
- ផ្ទះ អគារ និងសំណង់ដែលកំពុងត្រូវបានសាងសង់តិចជាង ៨០ (ប៉ែតសិប) ភាគរយ និងមិនទាន់បានប្រើប្រាស់
- អចលនទ្រព្យដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្ម ។

២- ម្ចាស់អចលនទ្រព្យទាំងអស់ ទោះត្រូវជាប់ ឬមិនត្រូវជាប់ពន្ធលើអចលនទ្រព្យក្តី ត្រូវបំពេញព័ត៌មានអចលនទ្រព្យរបស់ខ្លួនក្នុងទម្រង់លិខិតព័ត៌មានអចលនទ្រព្យផ្តល់ឱ្យដោយសាលាសង្កាត់ ហើយត្រូវប្រគល់ឱ្យសាលាសង្កាត់វិញ ក្នុងរយៈពេលយ៉ាងយូរ ១០ ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលទម្រង់លិខិតព័ត៌មានអចលនទ្រព្យនោះ ។

៣- អចលនទ្រព្យដែលផុតពីចំណុចទី ១ ខាងលើ និងមានតម្លៃលើសពី ១០០ លានរៀល ត្រូវចុះបញ្ជីដាក់លិខិតប្រកាស និងបង់ពន្ធទៅសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត ដែលស្ថិតនៅក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax 855-23-427 798
mef_adm@yahoo.com

ក. ការចុះបញ្ជីត្រូវភ្ជាប់មកជាមួយនូវឯកសារថតចម្លង ដូចខាងក្រោម :

- អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬសំបុត្របញ្ជាក់កំណើត ឬលិខិតឆ្លងដែនសម្រាប់ជនបរទេស
- សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅ
- បណ្ណសម្គាល់សិទ្ធិ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុដែលចេញដោយរដ្ឋបាលសុរិយោដី ឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យដែលបញ្ជាក់ដោយអាជ្ញាធរឃុំ-សង្កាត់ឡើងទៅ ។

ខ. ការដាក់លិខិតប្រកាសពន្ធលើអចលនទ្រព្យ :

- ត្រូវធ្វើតាមទម្រង់កំណត់ដោយរដ្ឋបាលសារពើពន្ធ ចំនួន ២ ច្បាប់ ដែលមួយច្បាប់សម្រាប់រក្សាទុកនៅរដ្ឋបាលសារពើពន្ធ និងមួយច្បាប់ទៀតសម្រាប់ម្ចាស់អចលនទ្រព្យ។
- ម្ចាស់អចលនទ្រព្យត្រូវធ្វើការគណនាប្រាក់ពន្ធដោយខ្លួនឯង ដោយផ្អែកលើតម្លៃអចលនទ្រព្យដែលបានកំណត់ ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យ ។

៤. ចំពោះម្ចាស់អចលនទ្រព្យដែលមានអចលនទ្រព្យច្រើន ម្ចាស់អចលនទ្រព្យ ត្រូវចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើអចលនទ្រព្យ ដាច់ដោយឡែកៗពីគ្នា ។

៥. ពន្ធលើអចលនទ្រព្យ ត្រូវប្រមូលប្រចាំឆ្នាំតាមអត្រា ០,១ (សូន្យក្បៀសមួយ) ភាគរយ នៃមូលដ្ឋានគិតពន្ធ ។ មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ ត្រូវកំណត់តាមតម្លៃអចលនទ្រព្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០ លានរៀល សម្រាប់អចលនទ្រព្យមួយ ។ តម្លៃអចលនទ្រព្យក្នុងភូមិសាស្ត្ររដ្ឋបាលនីមួយៗ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងបិទផ្សាយនៅតាមគ្រប់សាលាសង្កាត់ពាក់ព័ន្ធ និងសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត ។

៦. ម្ចាស់អចលនទ្រព្យ ត្រូវបង់ប្រាក់ពន្ធ ជាប្រាក់រៀល ដោយ :

ក. នៅរាជធានីភ្នំពេញ អាចបង់ពន្ធផ្ទាល់នៅសាខាពន្ធដារខណ្ឌដែលស្ថិតក្នុងភូមិសាស្ត្រ ដែលអចលនទ្រព្យនោះស្ថិតនៅ ឬអាចបង់ពន្ធនៅធនាគារជាតិនៃកម្ពុជា តាមលេខគណនីរបស់សាខាពន្ធដារខណ្ឌនោះ ។

ខ. នៅក្រុងនៃខេត្ត អាចបង់ពន្ធផ្ទាល់នៅសាខាពន្ធដារខេត្តដែលស្ថិតក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ ។

អាស្រ័យហេតុនេះ សូមម្ចាស់អចលនទ្រព្យ មេត្តាអញ្ជើញបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធសម្រាប់ឆ្នាំ២០១១ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ និងឱ្យបានចប់សព្វគ្រប់ត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១១ កុំបីខាន ។

ក្នុងករណីមានចម្ងល់ទាក់ទិននឹងពន្ធលើអចលនទ្រព្យនេះ សូមម្ចាស់អចលនទ្រព្យ មេត្តាទាក់ទងផ្ទាល់ជាមួយសាខាពន្ធដារខេត្ត-ខណ្ឌ ដែលស្ថិតក្នុងភូមិសាស្ត្រដែលអចលនទ្រព្យនោះស្ថិតនៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

**ចំលងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣២៥៨ ពណ.ចបព

ភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយជាបុត្រសម្ព័ន្ធនៃក្រុមហ៊ុន FREELAND UNIVERSAL LIMITED (BVI) ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **លីបើរ - បាហ្វ ហ្វរីសទ្រី & ផ្លេនថេសិន**
**LIBER - BUF FORESTRY & PLANTATION Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៣៥៦E/២០១០ ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
លោក TSENG, CHING-CHEN "តតិយជន" ប្រធានក្រុមប្រឹក្សាភិបាល
លោក LEE, MON-LUN "តតិយជន" អភិបាល
លោក CHEN, WANG-CHI "តតិយជន" អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤.000.000.000 រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១២៨ G ១០ វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហារណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម - តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពរបស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**គីម ស៊ីថន**

**<u>ចម្លងជូន</u>**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣២៦១ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **ផេស៊ីហ្វិក ហ្គ្រេស យ៉ញ-ស្តុក ខមភេនី លីមីធីត**
**PACIFIC GRACE JOINT-STOCK COMPANY LIMITED**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៣៩៣E/២០១០ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក PHAM QUOC LONG ប្រធានក្រុមប្រឹក្សាភិបាល
លោក NGUYEN THANH SON អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៩៣ C មហាវិថីម៉ៅសេទុង សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហារ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម។

៦. ចិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនិមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកលប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាកទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនិមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/.

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**រដ្ឋលេខាធិការ**

**គឹម_ស៊ីថន**

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"
- ល.ស.រ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣២៧២ ពណ.ចបព

ភ្នំពេញថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោមៈ

១- នាមករណ៍របស់ក្រុមហ៊ុន : **ផេស៊ីហ្វិក វិកថឺរី យ៉ញ-ស្តុក ខមភេនី លីមីធីត**
**PACIFIC VICTORY JOINT-STOCK COMPANY LIMITED**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. ១៣៩៦E/២០១០** ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន : លោក NGO THO NGUYEN ប្រធានក្រុមប្រឹក្សាភិបាល
លោក CHU DUC KHANG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ១៩៣ C មហាវិថីម៉ៅសេទុង សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុង និងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ

គីម សុីថន

**ចម្លងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស៖ - ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣២៦៦ ពណអ.ចបព

ភ្នំពេញថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០១០

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
## សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅតាមលក្ខខណ្ឌដូចខាងក្រោម:

១- នាមករណ៍របស់ក្រុមហ៊ុន : **អេច.អេច.ស៊ី.វី. អេគ្រីខលឈ័រ**
**H.H.C.V. AGRICULTURE Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. ១៩១៨KH/២០១០ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

២- អភិបាលក្រុមហ៊ុន :
លោក **ហួឡា សុភ័ណ** ប្រធានក្រុមប្រឹក្សាភិបាល
លោក **ទ៉ាន់ សំមិញ** អភិបាល
លោក **ឈុន ថាន់** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : លេខ ២៦ E ផ្លូវលេខ ៥៨៦ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហារណ៍ អាហរណ៍ទំនិញគ្រប់ប្រភេទ
-នាំចូលឱសថ សំភារៈ បរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ - ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនិធិពាណិជ្ជកម្ម - ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ កែច្នៃ ទិញ លក់គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជម្ងឺ
-បើកសាលារៀន
-ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស - សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសាលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ...

៦- ថិរវេលា : ៩៩ ឆ្នាំ

រាល់ដំណាច់ឆ្នាំនីមួយៗ អភិបាលក្រុមហ៊ុនមានកាតព្វកិច្ចមកតំកល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាព របស់ក្រុមហ៊ុននៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម ។

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬស្ថាប័នដែលគ្រប់គ្រងមុខ ជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងស្នាក់ការរបស់ក្រុមហ៊ុនពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
ជ. រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
អនុរដ្ឋលេខាធិការ

ហុ_សារ៉ាន់

**ចម្លងជូន**
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងបរិស្ថាន
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងទេសចរណ៍
- ក្រសួងសុខាភិបាល
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពត៌មាន
- ក្រសួងអប់រំ យុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលារាជធានីភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ "មុខការ"

ស.ស.រ - ឯកសារ - កាលប្បវត្តិ